# របាយការណ៍សកម្មភាពការងារប្រចាំខែ មិថុនា ឆ្នាំ ២០១៧ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

## I. ស្ថានភាពទូទៅ

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានមន្ត្រីសរុបចំនួន ១៧ រូប (ស្រី ០៥ រូប) ក្នុងនោះមន្ត្រីកម្មសិក្សា ចំនួន ០២ រូប (ស្រី ០១ រូប) ÷

- ចំនួនមន្ត្រីរាជការ ដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ÷ គ្មាន
- ចំនួនមន្ត្រីរាជការ ដែលបានទៅបំពេញបេសកកម្មនៅក្រៅប្រទេស ÷ ០១រូប
- ចំនួនមន្ត្រីរាជការ សម្រាកលំហែមាតុភាព ÷ គ្មាន
- ចំនួនឈឺ ÷ គ្មាន
- ចំនួនមន្ត្រីរាជការ ដែលបានសហប្រតិបត្តិការជាមួយអង្គការ និងកម្មវិធី ÷ គ្មាន

## II. លទ្ធផលការងារ

### 1. ការងារសវនកម្ម

- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៦ -២០១៧ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋ **នៅមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ០៤** រួមមាន ខេត្តកោះកុង កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។

### 2. ការងារប្រជុំ និងបណ្តុះបណ្តាល

ថ្នាក់ដឹកនាំ និងមន្ត្រី បានចូលរួមកិច្ចប្រជុំចំនួន ០២ លើក សិក្ខាសាលាចំនួន ០១ លើក និងបណ្តុះបណ្តាលចំនួន ០២ លើក÷

- **ការងារប្រជុំ**

- អនុប្រធាននាយកដ្ឋាន ០១រូប(ស្រី ០១រូប) ចូលរួមក្នុងកិច្ចប្រជុំស្តីពី ដំណើការរៀបចំការប្រលងជ្រើសរើសមន្ត្រីក្របខណ្ឌឆ្នាំ ២០១៧ នៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០៣
- អនុប្រធាននាយកដ្ឋាន និងប្រធានការិយាល័យ ០១ រូប (ស្រី ០១រូប) ចូលរួមក្នុងកិច្ចប្រជុំស្តីពី កែសម្រួលលើតារាងពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រង នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០១ ។

- **សិក្ខាសាលា**

- អនុប្រធាននាយកដ្ឋាន (ស្រី០១ រូប) ចូលរួមសិក្ខាសាលាស្តីពីទស្សនៈយេនឌ័រ និងអនុសញ្ញា ស៊ី-ដ នៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១៧ សាលប្រជុំ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង ។

- **បណ្តុះបណ្តាល**

- មន្ត្រីនាយកដ្ឋានចំនួន ០២ រូប (ស្រី ០១ រូប ) ចូលរួមវគ្គបណ្តុះបណ្តាល មុខវិជ្ជាជំនាញប្រើប្រាស់កម្មវិធី “ Advanced Microsoft Excel ” នៅថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី “1A” នៃទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- អនុប្រធានការិយាល័យ ០១ រូប (ប្រុស ០១ រូប ) ចូលរួមក្នុងវគ្គបណ្តុះបណ្តាលវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ នៅសាលាភូមិន្ទរដ្ឋបាល សម្រាប់ឆ្នាំ ២០១៧ ចាប់ពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៧ ដល់ថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៨ ។

### 3. កម្មវិធីផ្សេងៗ

- គ្មានសកម្មភាព ។